# ខ្មែរកម្ពុជាក្រោមសំណូមពររាជរដ្ឋាភិបាលកម្ពុជា ៦ចំណុច

រាជធានីភំពេញ  ព្រះរាជាណាចក្រកម្ពុជា - នៅក្នុងរបាយការណ៍ស្តីពីស្ថានភាពសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោមប្រចាំឆ្នាំ២០០៧ បានធ្វើសំណូមពរចំនួន៦ចំណុចដល់រាជរដ្ឋាភិបាលកម្ពុជាដែលក្នុងនោះជាសំខាន់សុំឱ្យមានការចាក់ផ្សាយពង្សាវតាកម្ពុជាតាមប្រព័ន្ធផ្សព្វផ្សាយនានារបស់រដ្ឋឱ្យបានយ៉ាងតិច ២ដងក្នុងមួយសប្តាហ៍ ។

សំណូមពរទាំង៦ចំណុចនោះ គឺទី១-សូមឱ្យចាក់ផ្សាយពង្សសាវតាកម្ពុជានៅតាមប្រព័ន្ធផ្សព្វផ្សាយនានារបស់រដ្ឋឱ្យបានយ៉ាងតិច២ដងក្នុងមួយសប្តាហ៍ ។ ទី២-សូមឱ្យរាជរដ្ឋាភិបាលដាក់បញ្ចូលពង្សសាវតានិងប្រវត្តិខ្មែរក្រោមទៅក្នុងកម្មវិធីអប់រំរបស់រដ្ឋ ។ ទី៣-សូមក្រសួងមហាផ្ទៃចេញគោលការណែនាំឯកភាពរួមមួយសំរាប់សមត្ថកិច្ចក្នុងការអនុវត្តន៍ច្បាប់សញ្ជាតិចំពោះខ្មែរកម្ពុជាក្រោមនៅកម្ពុជា ។ ទី៤-សូមឱ្យរដ្ឋាភិបាលយកចិត្តទុកដាក់ឱ្យខ្មែរកម្ពុជាក្រោមមានសិទ្ធិសេរីភាពដូចប្រជាពលរដ្ឋនៅកម្ពុជា ។ ទី៥-សូមឱ្យរដ្ឋាភិបាលពិនិត្យឡើងវិញនូវដីសម្បទានរបស់រដ្ឋដែលអ្នកទទួលសម្បទានមិនធ្វើការអភិវឌ្ឍន៍ត្រូវដកមកចែកជូនប្រជាជនក្រីក្រ។ និងទី៦-រដ្ឋគួរបង្កើតគោលនយោបាយចែកដីសម្បទានរបស់រដ្ឋឱ្យប្រជាពលរដ្ឋក្រីក្រឱ្យស្មើភាពប្រកបដោយតម្លាភាព ។

គួរបញ្ជាក់ផងដែរថា តាមការស្រាវជ្រាវរបស់អង្គការខ្មែរកម្ពុជាក្រោមការពារសិទ្ធិមនុស្សបានឱ្យដឹងថាប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម ដែលមករស់នៅព្រះរាជាណាចក្រកម្ពុជាមានប្រមាណ ១.៥០០.០០០នាក់ ហើយសមត្ថកិច្ចនគរបាលមូលដ្ឋានបានធ្វើសៀវភៅគ្រួសារ ប័ណ្ណស្នាក់នៅ លិខិតកំណើតនិងអត្តសញ្ញាណប័ណ្ណឱ្យពួកគាត់បានប្រហែល៦៥ភាគរយ នៅសល់បន្តិចបន្តួចប៉ុណ្ណោះ ។

មូលហេតុដែលធ្វើឱ្យបងប្អូនខ្មែរកម្ពុជាក្រោមចេះតែមករស់នៅប្រទេសកម្ពុជាមាន៣ចំណុចគឺ ទី១-ការញាំញីភាពក្រីក្រ ទី២-ការរំលោភបំពាននិងការគាបសង្កត់ពីអាជ្ញាធរវៀតណាម និងទី៣-កត្តារបបនយោបាយនិងភាពជ្រុលនិយមខាងសន្តិសុខខាងនយោ-បាយពីខាងអាជ្ញាធរវៀតណាម ។

ប្រភពអត្ថបទ: សារពត៌មានកម្ពុជាថ្មី

១២ មីនា ព.ស.២៥៥១

គ.ស.២០០៨